**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**
**លោកស្រី តន់ វ៉ាន់ស្រៀន អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក**
**និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសិកា ជិន ជ្រា ដែលត្រូវជាម្តាយបង្កើត លោកស្រី តន់ វ៉ាន់ស្រៀន អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានទទួលមរណភាពនៅថ្ងៃព្រហស្បតិ៍ ១២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ៥ ខែសីហា ឆ្នាំ២០២១ ក្នុងជន្មាយុ ៨០ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការជាមួយលោកស្រី និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ ឧបាសិកា ជិន ជ្រា ដែលជាម្តាយ និងជីដូនជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធឧបាសិកា ជិន ជ្រា បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកស្រី និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ សុក្រ ១៣ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ សីហា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**